ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

លេខ ៤២៣ សសរ កសក

# សេចក្តីសម្រេច
# ស្តីពី
# ការបង្កើតលេខាធិការដ្ឋានអចិន្ត្រៃយ៍របស់កម្មវិធីសកម្មភាពជាតិ ដើម្បីប្រយុទ្ធប្រឆាំងនឹងការធ្លាក់ចុះគុណភាពដី ឆ្នាំ២០១៨ - ២០២៧ (NAP)

## រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យ១១៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួងទៅជាអគ្គលេខាធិការដ្ឋាន ការតំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផល ឱ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានក្សេត្រសាស្ត្រ និងកែលម្អដីកសិកម្មឲ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និងការកែសម្រួលអគ្គនាយកដ្ឋានចម្ការកៅស៊ូទៅជាអគ្គនាយកដ្ឋានកៅស៊ូ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ៨១ អនក្រ.បក ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៩ ស្តីពីការកែសម្រួលមាត្រា២ មាត្រា២៥ មាត្រា២៦ និងមាត្រា៣៥ នៃអនុក្រឹត្យលេខ១៨៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ និងមាត្រា២៧ថ្មី នៃអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៧
- បានឃើញសេចក្តីសម្រេចលេខ២៣៦ សសរ កសក ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៩ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ស្តីពីការបង្កើតក្រុមការងារកម្មវិធីសកម្មភាពជាតិដើម្បីប្រយុទ្ធប្រឆាំងនឹងការធ្លាក់ចុះគុណភាពដី
- បានឃើញសេចក្តីសម្រេចលេខ២៣៧ សសរ កសក ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៩ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ស្តីពីការបង្កើតក្រុមការងារបច្ចេកទេសកម្មវិធីសកម្មភាពជាតិដើម្បីប្រយុទ្ធប្រឆាំងនឹងការធ្លាក់ចុះគុណភាពដី
- យោងកម្មវិធីសកម្មភាពជាតិដើម្បីប្រយុទ្ធប្រឆាំងនឹងការធ្លាក់ចុះគុណភាពដីឆ្នាំ២០១៨-២០២៧ ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០១៨ របស់រាជរដ្ឋាភិបាលកម្ពុជា
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## សម្រេច

**ប្រការ១._**

ត្រូវបានបង្កើតលេខាធិការដ្ឋានអចិន្ត្រៃយ៍របស់ក្រុមការងារកម្មវិធីសកម្មភាពជាតិដើម្បីប្រយុទ្ធប្រឆាំងនឹងការធ្លាក់ចុះគុណភាពដី ឆ្នាំ២០១៨-២០២៧ (NAP) ដែលមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១. ឯកឧត្តម មាស ពិសិដ្ឋ | អនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ប្រធាន |
| ២. លោក យី កុសល | អគ្គលេខាធិការរងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | អនុប្រធាន |
| ៣. លោក យៅ វេន | ប្រធានមជ្ឈមណ្ឌលព័ត៌មាន និងឯកសារកសិកម្ម | សមាជិក |
| ៤. កញ្ញា ឡូ សុខា | អនុប្រធាននាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ | សមាជិកា |
| ៥. លោក អំ ភិរម្យ | អនុប្រធាននាយកដ្ឋានគ្រប់គ្រងធនធានដីកសិកម្ម នៃអគ្គនាយកដ្ឋានកសិកម្ម | សមាជិក |
| ៦. លោកស្រី អ៊ឹម ម៉ារីឌី | ប្រធានការិយាល័យសហគមន៍ព្រៃឈើនៃរដ្ឋបាលព្រៃឈើ | សមាជិកា |
| ៧. លោក រឿន ចន្ថា | ប្រធានការិយាល័យការងារអន្តរជាតិនៃនាយកដ្ឋាន សហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ៨. លោក ចាន់ សេងប៊ុ | អនុប្រធានការិយាល័យគណនេយ្យនៃនាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុ | សមាជិក |
| ៩. លោក ចាន់ សំអុល | អនុប្រធានការិយាល័យហិរញ្ញកិច្ចនៃនាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុ | សមាជិក |
| ✓១០. លោក ឆាយ តុលា | អនុប្រធានការិយាល័យព័ត៌មានវិទ្យា និងបច្ចេកវិទ្យាទូរគមនាគមន៍ នៃមជ្ឈមណ្ឌលព័ត៌មាន និងឯកសារកសិកម្ម | សមាជិក |
| ១១. កញ្ញា សែត សាវឌី | អនុប្រធានការិយាល័យការងារអន្តរជាតិនៃនាយកដ្ឋាន សហប្រតិបត្តិការអន្តរជាតិ | សមាជិកា |
| ១២. លោក ខាត់ សុធារ៉ា | មន្ត្រីនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ១៣. លោក សោម ដារ៉ា | មន្ត្រីនាយកដ្ឋានផែនការ និងស្ថិតិ | សមាជិក |
| ១៤. លោក គង់ ចាន់រដ្ឋា | មន្ត្រីនាយកដ្ឋានកិច្ចការរដ្ឋបាល | សមាជិក |
| ១៥. កញ្ញា ឡុង កែវកន្និដ្ឋា | បុគ្គលិកកិច្ចសន្យានៃនាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុ | សមាជិកា |

**ប្រការ២._**

លេខាធិការដ្ឋានអចិន្ត្រៃយ៍របស់ក្រុមការងារ NAP មានភារកិច្ចដូចខាងក្រោម ៖

- សម្របសម្រួលរាល់កិច្ចការពាក់ព័ន្ធនឹងការអនុវត្ត NAP
- កសាងផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ
- ទំនាក់ទំនង និងសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍នានា
- រៀបចំ និងចាត់ចែងរាល់កិច្ចប្រជុំពាក់ព័ន្ធ ព្រមទាំងធ្វើកំណត់ហេតុ និងរបាយការណ៍
- ធ្វើរបាយការណ៍វឌ្ឍនភាពប្រចាំត្រីមាស ឆមាស និងប្រចាំឆ្នាំ ជូនគណៈកម្មាធិការតម្រង់ទិស ក្រុមការងារបច្ចេកទេស និងក្រុមការងារ NAP
- រៀបចំរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ
- លើកសំណើសុំជ្រើសរើសទីប្រឹក្សា ដើម្បីគាំទ្រដល់ការអនុវត្ត NAP ឲ្យមានប្រសិទ្ធភាព
- បង្កើតយន្តការ និងឧបករណ៍តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្ត NAP
- បំពេញភារកិច្ចផ្សេងៗទៀត តាមការចាត់តាំងរបស់ប្រធានក្រុមការងារ NAP។

**ប្រការ៣.**_

អនុប្រធាន សមាជិក សមាជិកា ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។ ក្នុងករណីប្រធានអវត្តមាន អនុប្រធានអាចដឹកនាំជំនួស តាមការប្រគល់ភារកិច្ចរបស់ប្រធាន។

**ប្រការ៤.**_

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៥.**_

អគ្គលេខាធិការ អគ្គាធិការ ប្រធានគ្រប់អង្គភាពដែលពាក់ព័ន្ធក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ច័ន្ទ ៦ កើត ខែ [illegible] ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែ ៧ ឆ្នាំ២០១៩

**រដ្ឋមន្ត្រី**
**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**វេង សាខុន**

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងបរិស្ថាន
- ក្រសួងធនធានទឹក និងឧតុនិយម
- គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា
- ដូចប្រការ៥
- ឯកសារ កាលប្បវត្តិ